# សេចក្តីសង្ខេបនៃដំណើរការបណ្តឹងភាគីទីបី

អេឌីដាស (adidas) មានគោលការណ៍និងការអនុវត្តន៍និរន្តរភាពផ្ទៃក្នុង ព្រមទាំងស្តង់ដារការងារដែលក្រុមហ៊ុនផ្គត់ផ្គង់ អ្នកទទួលបានអាជ្ញាប័ណ្ណ ភ្នាក់ងារ និងអ្នកផ្តល់សេវាផ្សេងទៀតត្រូវតែអនុវត្តតាម ។

រាល់ការអនុវត្តន៍ផ្ទុយពីស្តង់ដារ ឬជាសញ្ញាណណាមួយ ឬការអនុវត្តន៍ជាក់ស្តែងដែលរំលោភសិទ្ធិមនុស្ស ហើយមានទំនាក់ទំនងទៅនឹងប្រតិបត្តិការ ការផលិត ឬសេវាកម្មរបស់adidas អាចលើកជាបណ្តឹងឡើងតាមរយៈបណ្តឹងតវ៉ាភាគីទីបីដែលចែងដូចខាងក្រោម:

**តើនរណាអាចធ្វើបណ្តឹងបាន?**

បុគ្គល ឬអង្គភាពណាមួយដែលរងផលប៉ះពាល់ដោយផ្ទាល់ពីបញ្ហា ឬអង្គការដែលតំណាងឱ្យបុគ្គល ឬសហគមន៍ដែលរងផលប៉ះពាល់ដោយផ្ទាល់ណាមួយ អាចធ្វើជាពាក្យបណ្តឹងបាន។

**តើបណ្តឹងមានដំណើរការយ៉ាងដូចម្តេច?**

ពាក្យបណ្តឹងគួរមានមូលដ្ឋានច្បាស់លាស់ ។ និយោជិតដែលលើកជាបណ្តឹងហើយធ្វើការក្នុងរោងចក្រដែលផលិតឲ្យ adidas គួរប្រើលេខទូរស័ព្ទអេឌីដាសដែលបានបិតផ្សាយនៅកន្លែងការងារ។ រាល់បណ្តឹងទាំងអស់អាចផ្ញើរសារទៅកាន់ sustainability@adidas-Group.com ឬសំបុត្រ ឬទូរស័ព្ទនៅលេខដែលមានភ្ជាប់នៅទំព័រទី២។ ពាក្យបណ្តឹងគួរតែភ្ជាប់មកជាមួយព័ត៍មានពាក់ព័ន្ធទាំងអស់ និងពន្យល់ពីតម្រូវការដែលចង់បាន។ ពាក្យបណ្តឹងមិនចាំបាច់សរសេរជាភាសាអង់គ្លេសនោះទេ គឺអាចសរសេរជាភាសាជាតិខ្លួនផ្ទាល់បាន ។ ពាក្យបណ្តឹងនឹងត្រូវដោះស្រាយដោយបើកចំហរ និងមានតម្លាភាព លើកលែងតែក្នុងករណីដែលមានហានិភ័យនៃការសងសឹក ទើបការដោះស្រាយបណ្តឹងមិនធ្វើជាសាធារណៈ។

**ជំហានក្នុងការដោះស្រាយពាក្យបណ្តឹងរួមមាន:**

1. ការទទួលពាក្យបណ្តឹង
2. ការវាយតម្លៃហេតុផលនៃបណ្តឹង និតិវិធីដែលអេឌីដាសដោះស្រាយក្នុងករណីដែលបណ្តឹងត្រូវបានទទួលយក
3. ករណីដែលបណ្តឹងត្រូវបានទទួលយក
   ព័ត៍មានទាំងអស់នឹងត្រូវត្រួតពិនិត្យឡើងវិញដោយប្រុងប្រយ័ត្នដោយផ្នែកកិច្ចការសង្គមនិងបរិស្ថាន(SEA) ។ ការត្រួតពិនិត្យអាចអាចប្រើពេលមួយសប្តាហ៍ ឬច្រើនជាងមួយសប្តាហ៍។
4. ការឆ្លើយតបនៃពាក្យបណ្តឹងនឹងធ្វើឡើងដោយផ្អែកលើការរកឃើញពីការពិនិត្យឡើងវិញនៃពាក្យបណ្តឹង។
5. ក្នុងករណីចំបាច់SEA នឹងចុះអង្កេតដោយផ្ទាល់ ឬក៏ជ្រើសយកភាគី៣ដើម្បីចុះអង្កេត ។ គោលបំណងក្នុងការចុះអង្កេត គឺដើម្បីប្រមូលព័ត៍អោយបានគ្រប់គ្រាន់ដើម្បីដោះស្រាយបណ្តឹងដោយផ្អែកលើអង្គហេតុពេញលេញនៃបណ្តឹង។
6. ក្នុងដំណាក់កាលនេះ ពាក្យបណ្តឹងអាចដោះស្រាយតាមរយៈការព្រមព្រៀងរួម។ បើសិនគ្មានការព្រមព្រៀងរវាងភាគីនោះទេ adidas នឹងធ្វើការសំរេចលទ្ធផលនៃបណ្តឹង។
7. ក្នុងករណីដែលadidas ជាអ្នកបណ្តាល ឬចូលរួមដោយផ្ទាល់ចំពោះការរំលោភបំពាន យើងខ្ញុំនឹងស្វែងរកការបង្ការ ឬការកាត់បន្ថយឱកាសនៃផលប៉ះពាល់ ។
8. ក្នុងករណីផលប៉ះពាល់អវិជ្ជមានបានកើតឡើង adidasនឹងចូលរួមយ៉ាងសកម្មនៅក្នុងការដោះស្រាយ។ ក្នុងករណីadidas មិនមែនជាអ្នកបណ្តាលឱ្យ ឬរួមចំណែកដោយផ្ទាល់ដល់ការរំលោភបំពាន យើងខ្ញុំនឹងលើកទឹកចិត្តឱ្យដៃគូអាជីវកម្មដែលបានបណ្តាល ឬចូលរួមចំណែកទៅនឹងផលប៉ះពាល់ ធ្វើការការពារ ឬកាត់បន្ថយការកើតមានឡើងវិញនៃផលប៉ះពាល់ ។

យោងទៅលើភាពស្មុគស្មាញនៃបណ្តឹង ពាក្យបណ្តឹងមួយអាចត្រូវចំណាយពេលពី3សប្តាហ៍ឬច្រើនជាងនេះ ដើម្បីធ្វើការវាយតម្លៃ ស៊ើបអង្កេត និងបន្តដំណើរការ មុនពេលឈានចូលកិច្ចព្រមព្រៀងបន្ថែមទៀតអំពីការកែតំរូវ។

**សកម្មភាពត្រួតពិនិត្យ**

អាស្រ័យលើប្រភេទនៃការកែតំរូវដែលបានព្រមព្រៀង adidasនឹងស្វែងរកការព្រមព្រៀងលើវិធីត្រួតពិនិត្យដើម្បីធានាថាការកែតំរូវស្ថិតក្នុងកាលកំណត់ដែលបានព្រមព្រៀងគ្នា។ ផ្នែកSEA នឹងត្រួតពិនិត្យនូវលទ្ធផលបានព្រមព្រៀង ឬចាត់តាំងភាគីទីបីមួយដែលទុកចិត្តដើម្បីត្រួតពិនិត្យ។

ក្នុងករណីបុគ្គល ឬអង្គការដែលគិតថាពួកគេបានរងការគំរាមកំហែង ឬក៏រងការសងសឹក ដោយសារតែការដាក់ពាក្យបណ្តឹងមកកាន់អេឌីដាស ពួកគាត់អាចទំនាក់ទំនងមកកាន់SEA និងផ្តល់នូវព័ត៌មានលម្អិតដែលបានកើតឡើង។ SEA នឹងធ្វើការស៊ើបអង្កេត ក្នុងករណីដែលមានភស្តុតាងច្បាស់លាស់ នឹងរៀបចំអោយការកែតំរូវនូវស្ថានភាពនេះ ។

**បណ្តឹងបន្ត**

ប្រសិនបើភាគីណាមួយមិនពេញចិត្តនឹងរបៀបដែលដោះស្រាយបណ្តឹង ពួកគេអាចលើកឡើងមកផ្នែកSEA។ SEA នឹងពិនិត្យករណីនេះ ហើយទាក់ទងទៅផ្នែកអ្នកប្រឹក្សាទូទៅរបស់adidas ធ្វើការសំរេចចិត្តជាចុងក្រោយ។

**វិធីផ្សេងទៀតដើម្បីតវ៉ា**

បុគ្គលឬអង្គការដែលអាចប្រើបណ្តាញឯករាជ្យផ្សេងទៀតដើម្បីប្តឹងតវ៉ារួមមាន Third Party Complaint Process of the Fair Labor Association (FLA) និង OECD National Contact Point for Germany.

**សិទ្ធិស្របច្បាប់**

បុគ្គល ក្រុម ឬសហគមន៍ដែលដាក់ពាក្យបណ្តឹងមកអេឌីដាស នៅតែមានសិទ្ធិស្របច្បាប់ ក្នុងការដាក់ពាក្យទៅតុលាការ ឬយន្តការរដ្ឋបាលក្នុងស្រុក។ ប្រសិនបើជាបញ្ហាផ្នែកច្បាប់ ឬការបកស្រាយផ្លូវច្បាប់គឺជាធាតុសំខាន់មួយនៃការតវ៉ា ភាគីគួរតែអនុវត្តតាមយន្តការច្បាប់ជាមុន។

**ទំនាក់ទំនងមកកាន់adidas**

| អឺរ៉ុប អាហ្វ្រិក មជ្ឈិមបូព៌ា | អាស៊ីប៉ាស៊ីហ្វិក | អាមេរិក |
|---|---|---|
| adidas<br>Social & Environmental Affairs<br>Adi-Dassler-Straße 1<br>91074 Herzogenaurach<br>Germany<br><br>Attention: Mr Chris Buckley | adidas<br>Social & Environmental Affairs<br>10 Floor, The Quayside<br>Kwun Tong<br>Hong Kong SAR<br><br>Attention: Mr William Anderson | adidas<br>Social & Environmental Affairs<br>5055 North Greeley Avenue<br>OR 97217<br>USA<br><br>Attention: Mr Selcuk Buyukozer |
| Director, Social & Environmental Affairs<br><br>Phone: +49 16097093841 | Vice President, Social & Environmental Affairs<br><br>Phone: +852 2302 8654 | Vice President, Social & Environmental Affairs<br><br>Phone: +1 7813630544 |